ក្រុមការងារបច្ចេកទេសចំរុះសំរាប់កំណែទំរង់ព្រៃឈើ

ឯកសារសំរាប់កិច្ចប្រជុំលើកទី១នៃ

វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា

ថ្ងៃទី ១៩-២០ មិថុនា ២០០៧

បំរែបំរួលគំរបព្រៃឈើកម្ពុជាក្នុងឆ្នាំ២០០២-២០០៦

គំរបព្រៃឈើក្នុងឆ្នាំ២០០២

គំរបព្រៃឈើក្នុងឆ្នាំ២០០៦

បំរែបំរួលគំរបព្រៃឈើ ពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៦

1.1 ប្រវត្តិ

រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចាត់វិធានការពង្រឹង ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានព្រៃឈើរបស់ប្រទេសប្រកបដោយចីរភាព ដោយផ្អែកលើសសរស្តម្ភជាយុទ្ធសាស្ត្របីសំខាន់:

- ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព: ជាមួយការត្រួតពិនិត្យតាមដានម៉ឹងម៉ាត់ចំពោះការធ្វើអាជីវកម្មព្រៃឈើ និងគ្រប់គ្រងព្រៃឈើ ដោយធានាឱ្យមានការរក្សាព្រៃបំរុងទុកគ្រប់គ្រាន់សំរាប់ ការប្រើប្រាស់ក្នុងស្រុក ការការពារទប់ទល់គ្រោះរាំងស្ងួត និងទឹកជំនន់ ក៏ដូចជាធានាឱ្យមានតំបន់ដីសើម សំរាប់ជាជំរកត្រី។
- ការការពារធនធានធម្មជាតិ ជីវចំរុះ និងប្រភេទរុក្ខជាតិនិងសត្វដែលកំពុងរងគ្រោះ។
- ជំរុញនិងអភិវឌ្ឍន៍សហគន៍ព្រៃឈើដែលគ្រប់គ្រងដោយប្រជាជនមូលដ្ឋាន និងប្រកបដោយតម្លាភាព។

ដើម្បីសំរេចនិរន្តរភាពនៃបរិស្ថាននៃគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា ក្នុងចំណុចទី៧ដែលពាក់ព័ន្ធនិងធនធានព្រៃឈើ បានកំណត់សំរាប់ឆ្នាំ ២០១៥ សំខាន់ៗរួមមាន រួមមាន:

i. រក្សាឱ្យបានគំរបព្រៃឈើជាតិ ចំនួន៦០%នៃផ្ទៃប្រទេស។

ii. រក្សាឱ្យបាន តំបន់ការពារចំនួន២៣កន្លែង ដែលមានទំហំ 3,3 លាន ហិចតា។

iii. រក្សាឱ្យបាន តំបន់ព្រៃការពារថ្មីចំនួន៦ កន្លែង ដែលមានទំហំ 1,35 លានហិចតា។

iv. បង្កើនចំនួនរុក្ខារក្សឱ្យបានចំនួន ១២០០ នាក់សំរាប់ឈ្មួញតក្នុងតំបន់ការពារ និង៥០០នាក់សំរាប់ឈ្មួញតក្នុងព្រៃការពារ។

v. កាត់បន្ថយការពឹងអាស្រ័យលើការប្រើប្រាស់ថាមពលអុស នៅត្រឹម ៥២%។

ក្នុងខែធ្នូ ឆ្នាំ២០០៦ ក្រុមការងារបច្ចេកទេសចំរុះសំរាប់កំណែទំរង់ព្រៃឈើ (TWG-F&E) បានអនុម័តផែនការសកម្មភាព រយៈពេល៤ឆ្នាំ ២០០៧-១០ សំរាប់វិស័យព្រៃឈើនិងបរិស្ថាន ដែលស្របនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បន្ទាប់ពីបានធ្វើការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអ្នកពាក់ព័ន្ធជាច្រើននោះ។ ផែនការនេះផ្តល់នូវក្របខ័ណ្ឌទូលំទូលាយមួយសំរាប់សកម្មភាពអាទិភាព និង ឱកាសវិនិយោគទុនក្នុងវិស័យព្រៃឈើ។

1.2 ការកែប្រែប្រួលគំរបព្រៃឈើកម្ពុជា

ក្នុងឆ្នាំ១៩៦៥ ព្រៃឈើបានគ្របដណ្ដប់ប្រមាណ ៧៣%នៃផ្ទៃប្រទេស។ ដើម្បីត្រួតពិនិត្យតាមដានការបាត់បង់ដីព្រៃ រដ្ឋបាលព្រៃឈើបានធ្វើការ វាយតំលៃគំរបព្រៃឈើជាច្រើនលើក: ក្នុងឆ្នាំ១៩៩២/៩៣ ក្នុងឆ្នាំ១៩៩៦/៩៧ ក្នុងឆ្នាំ២០០០ (ផ្ទៃកខ្លះ១) និងក្នុងឆ្នាំ ២០០២។ គំរបព្រៃឈើកម្ពុជាបានថយចុះមកប្រហែល៦១%ក្នុងឆ្នាំ២០០២។ ការបង់បាត់គំរបព្រៃគឺស្របគ្នានិងការប្រែប្រួលការប្រើប្រាស់ដីដែលកើនឡើង ដោយសារ កំណើនប្រជាជន និងការអភិវឌ្ឍន៍សេដ្ឋកិច្ច ដូចនៅក្នុងបណ្ដាប្រទេសជាច្រើននោះ។

បញ្ហាសំខាន់ គឺគ្មានការធានាលើកម្មសិទ្ធិដីធ្លី និងសិទ្ធិប្រើប្រាស់ដីធ្លីមិនច្បាស់លាស់ កំពុងតែរំខានដល់ការខិតខំរបស់កម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រនៅជនបទដើម្បីធានាសុវត្ថិភាពជីវភាពរបស់គេ។ ការពង្រីកដីកសិកម្ម ការធ្វើអាជីវកម្មឈើល្មើសច្បាប់ ការសាងសង់ផ្លូវដូចជ្យីត និងកំណើនតំរូវការដីធ្លី គូបផ្សំនិងកំណើនវិនិយោគទុនបរទេសផ្ទាល់មកពីអាស៊ីអគ្នេយ៍ជាប់ជាបន្តនោះ បានបណ្ដាលឱ្យព្រៃឈើបន្តបាត់បង់តទៅទៀត ហើយក៏បណ្ដាលឱ្យសហគមន៍ដែលពឹងអាស្រ័យលើធនធានព្រៃឈើប្រឈមនិងភាពងាយរងគ្រោះកាន់តែខ្លាំងឡើង។ ដូច្នេះ ជាការចាំបាច់គឺ ត្រូវធានាឱ្យមានការគ្រប់គ្រងប្រកបដោយនិរន្តរភាពនិងការប្រើប្រាស់ធនធានព្រៃឈើដោយសមធម៌ ដើម្បីលើកកំពស់ការចិញ្ចឹមជីវិតនៅជនបទ និងជំរុញឱ្យមានការអភិវឌ្ឍន៍សេដ្ឋ

កិច្ច-សង្គមដោយតុល្យភាពនៅកម្ពុជា។ ប្រព័ន្ធគ្រប់គ្រងព្រៃឈើពីអតីតកាល មិនបានរួមចំណែកគ្រប់គ្រាន់ដល់ការសំរេចគោលបំណងនយោបាយទាំងនេះទេ (Independent Forest Sector Review, 2004)។

1.3 បំរែបំរួលគំរបព្រៃឈើពីឆ្នាំ២០០២ដល់ឆ្នាំ២០០៦

កិច្ចប្រជុំលើកទី១០នៃក្រុមការងារបច្ចេកទេសចំរុះសំរាប់កំណែទំរង់ព្រៃឈើកាលពីថ្ងៃទី២៦ កញ្ញា ២០០៦ បានអនុម័តគាំទ្រដល់ការវាយតំលៃគំរបព្រៃឈើឆ្នាំ២០០៥/០៦ដោយមានជំនួយបរិញ្ញាបប្ទានពីអង្គការដានីដានៃរាជរដ្ឋាភិបាលដាណឺម៉ាក។ ការិយាល័យគ្រប់គ្រងទីជំរាលនិងដីព្រៃនៃរដ្ឋបាលព្រៃឈើ បានធ្វើការវាយតំលៃបំរែបំរួលគំរបព្រៃឈើ ដោយប្រើបានរូបភាពផ្កាយរណប Landsat ETM+ data (រូបភាពទី១)[1]។ (ឯកសារបាយការណ៍មាននៅក្នុងគេហទំព័រ www.twgfe.org).

រូបភាពទី១: រូបភាពផ្កាយរណប Landsat 7

ការត្រួតពិនិត្យគុណភាពនិងការផ្ទៀងផ្ទាត់ទិន្នន័យ ពីក្រុមជំនាញការព័ត៌មានភូមិសាស្ត្រឯកភាជ្យមកពីសាកលវិទ្យាល័យ Copenhagen បានសន្និដ្ឋានក្នុងរបាយការណ៍ថា: *"អ្នកឯកទេសព័ត៌មានទីនៃការិយាល័យគ្រប់គ្រងទីជំរាលនិងដីព្រៃ ធ្វើការងារបានល្អណាស់ ក្នុងការធ្វើផែនទី។ ក៏ប៉ុន្តែ ការកែលំអមួយចំនួនទៀត អាចធ្វើទៅបាន ដោយប្រើលទ្ធភាពវិសាលគមច្រើនមុខ នៃរូបភាពផ្កាយរណប ដែលជាការលំបាកក្នុងការធ្វើចំណាត់ថ្នាក់ដោយភ្លេកតែមួយមុខនោះ"*។ ការប្តូរទៅប្រើវិធីសាស្ត្រស្វ័យ ប្រវត្តិជាងនេះ ធានាថាទទួលបានលទ្ធផលល្អជាងនេះ[2]។ ការកសាងសមត្ថភាព បីលើក បានដោះស្រាយអំពីការខ្វះចន្លោះនៃសមត្ថភាពនេះ[3]។

---

1 Additional methodological details are presented in *Progress Report on Forest Cover Assessment for year 2005/2006*. FA, Phnom Penh, November 2006.

2 GRAS A/S, 2007a. Accuracy Assessment Report. March 2007. University of Copenhagen, Copenhagen.

3 GRAS A/S, 2007b. Capacity Building Report. March 2007. University of Copenhagen, Copenhagen.

1.4 ការសង្ខេបនៃលទ្ធផល

- ពីឆ្នាំ២០០២ ដល់ឆ្នាំ ២០០៦ គំរបព្រៃឈើបានថយចុះពី៦១% មក ៥៩%នៃផ្ទៃប្រទេសសរុប(តារាង១ និងរូបទី២)។ ដូច្នេះ គំរបព្រៃឈើថយចុះបន្តិច ក្រោមគោលដៅអភិវឌ្ឍន៍សហវិស្សរ៍ គឺ៦០% នោះ។
- ការបាត់បង់ ២%នៃគំរបព្រៃឈើ គឺ ត្រូវបានិងការជាន់ស្មានការបាត់បង់ព្រៃចំនួន ៣៧៣.៥១០ហត។ ការបាត់បង់ព្រៃភាគច្រើន គឺកើតឡើងក្នុងភាគពាយ័ព្យនៃប្រទេស (គឺខេត្ត បន្ទាយមានជ័យ ឧត្តរមានជ័យ និងក្រុងប៉ៃលិន)។
- អត្រាប្រចាំឆ្នាំនៃការបាត់បង់ព្រៃឈើ មានប្រមាណ ០.៥% គឺតិចជាងតួរលេខរបស់អង្គការ FAO ដែលជាន់ស្មានថាមានប្រមាណ ១.៣% នោះ។

តារាងទី១: ការជាន់ស្មានគំរបព្រៃឈើពីឆ្នាំ ១៩៦៥ ដល់ ២០០៦

លរ	ឆ្នាំវាយតំលៃ	ដី				ដីសរុប Ha
		ដីព្រៃ		ដីគ្មានព្រៃ		
		Ha	%	Ha	%	
1	1965	13,227,100	73.04	4,883,400	26.96	18,110,500
2	1992/93	10,859,695	59.82	7,293,290	40.18	18,152,985
3	1996/97	10,638,209	58.60	7,514,776	41.40	18,152,985
4	2002	11,104,293	61.15	7,056,383	38.85	18,160,677
5	2005/06	10,730,781	59.09	7,429,893	40.91	18,160,674

រូបទី២: បំរែបំរួលគំរបព្រៃឈើពីឆ្នាំ ១៩៦៥ដល់២០០៦

1.5 ការសន្និដ្ឋាន

ការវាយតំលៃគំរបព្រៃឈើឆ្នាំ២០០៥/០៦ របស់រដ្ឋបាលព្រៃឈើ បង្ហាញឱ្យឃើញថា ចាប់ឆ្នាំ២០០២ ដល់ឆ្នាំ២០០៦ ប្រទេសកម្ពុជាបានបាត់បង់គំរបព្រៃ ចំនួន ២% គឺមិនមែន២៩% ដែលលើកឡើងក្នុងរបាយការណ៍ផ្សេងៗនាពេលថ្មីៗនេះទេ។

រាជរដ្ឋាភិបាលកម្ពុជា កំពុងបន្តសកម្មភាពកែទំរង់ព្រៃឈើ និងអនុវត្តច្បាប់ ដែលជាផ្នែកសំខាន់មួយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០។ សកម្មភាពទាំងនេះ គឺសំដៅកែលំអ ការកំណត់ព្រំប្រទល់ព្រៃឈើ ការបង្កើនសហគមន៍

ព្រៃឈើ ការការពារនិងការគ្រប់គ្រងមួយភាគបួននៃផ្ទៃក្រឡាសរុបសំរាប់គោលបំណងអភិរក្ស ការអភិវឌ្ឍន៍តំរូនៃការផ្តល់សេវាកម្ម ការសិក្សាទីផ្សារសំរាប់ជនក្រីក្រ ការអភិវឌ្ឍន៍សមត្ថភាព និងការត្រួតពិនិត្យតាមដានឧក្រិដ្ឋកម្មព្រៃឈើ ។

ដោយសារគ្មានការតាំទ្រពីដៃគូអភិវឌ្ឍន៍ សំរាប់ការតាមដានឯករាជ្យ តាំងពីដើមឆ្នាំ២០០៦មក រដ្ឋបាលព្រៃឈើបានបន្ធ្វើការតាមដានត្រួតពិនិត្យឧក្រិដ្ឋកម្មព្រៃឈើ ដោយខ្លួនឯង (រូបភាពទី៣) ។

រូបទី៣: និន្នាការថយចុះនៃបទឧក្រិដ្ឋកម្មព្រៃឈើ

ការត្រួតពិនិត្យព្រៃឈើឯករាជ្យកាលពីឆ្នាំ២០០៦ សន្និដ្ឋានថា ប្រព័ន្ធផ្ទៀងផ្ទាត់ ត្រូវតែធ្វើការពិចារណាឡើងវិញអំពីតំលៃនៃដំណោះស្រាយផ្ទុយច្បាប់ ហើយត្រូវយកចិត្តទុកដាក់ខ្លាំងឡើងដល់ *"ការរៀបចំកំលាំងរួបរួមក្នុងស្រុកឱ្យបានរឹងមាំ ដោយរួមផ្សំជាមួយការប្តេជ្ញាចិត្តគ្រប់ក្រាន់របស់រដ្ឋាភិបាលក្នុងការកែទំរង់"*[4] ។ នេះជាអនុសាសន៍ពាក់ព័ន្ធមួយដែលមានសារសំខាន់ណាស់សំរាប់ជំរុញឱ្យដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិ ត្រូវតាំទ្រដល់ផែនការសកម្មភាពឆ្នាំ២០០៧-១០ របស់ក្រុមការងារបច្ចេសចំរុះសំរាប់កំណែទំរង់ព្រៃឈើ ។

រដ្ឋបាលព្រៃឈើប្តេជ្ញាបន្តអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីអភិវឌ្ឍនីវិស័យព្រៃឈើ ។ រដ្ឋបាលព្រៃឈើតស៊ូគ្រប់គ្រងនិងអភិរក្សព្រៃឈើកម្ពុជាឱ្យមាននិរន្តរភាព និងជាវិភាគទានចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតាមជនបទ ។ ក្រុមការងារបច្ចេកទេសចំរុះសំរាប់កំណែទំរង់ព្រៃឈើ សូមអំពាវនាវដល់ដៃគូ អភិវឌ្ឍន៍ជាតិ និងអន្តរជាតិទាំងអស់ មេត្តាបន្តកិច្ចសហប្រតិបត្តិការរបស់ខ្លួន ដោយតាំទ្រដល់ដំណើរការកែទំរង់ព្រៃឈើជាតិ ។

---

4 Luttrell, C. and Brown, D., 2006. *The experience of Independent Forest Monitoring in Cambodia*. VERIFOR/ODI/RECOFTC/CIFOR/CATIE: 27

ឧបសម្ព័ន្ធ១: ការចាត់ថ្នាក់ប្រភេទគំរបព្រៃឈើ

ព្រៃស្រោង: ជាព្រៃដែលមានច្រើនស្រទាប់ ។ ដើមឈើក្នុងព្រៃនេះមានស្លឹកបៃតងជាប់ជានិច្ចពេញមួយឆ្នាំ ។ ព្រៃប្រភេទនេះ រួមមាន ព្រៃស្តុកតំបន់ទំនាបត្រូពិច ព្រៃស្រោងលើភ្នំ ព្រៃស្រោងស្ងួត និងព្រៃនៅតាមជ្រោះជ្រលងស្ទឹង ។

ព្រៃពាក់កណ្តាលស្រោង: ជាព្រៃឈើពាក់កណ្តាលបៃតង មានដើមឈើចំរុះ រវាងប្រភេទឈើព្រៃបៃតងនិងប្រភេទឈើព្រៃល្បោះ ដែលមានភាគរយប្រែប្រួលពី៣០%ទៅ៧០% ។ ប្រភេទព្រៃពាក់កណ្តាលស្រោងនេះ នៅតែមានពណ៌បៃតងពេញមួយឆ្នាំ ទោះបីជា ប្រភេទឈើព្រៃល្បោះ មានសមាសភាពភាគរយខ្ពស់ជាងក៏ដោយ ។

ព្រៃល្បោះ: ជាព្រៃមានដើមឈើជ្រុះស្លឹក រួមមានប្រភេទឈើព្រៃល្បោះស្ងួត និងប្រភេទឈើព្រៃអំបូរឈើផ្ទៃមានស្នាបពីរ ។ ព្រៃល្បោះជុំវិញ្ញកបស់វា តិចតួច ឬទាំងអស់ នៅរដូវប្រាំង ។ ជាទូទៅ ព្រៃនេះតែងមានភ្លើងឆេះបណ្តាលមកពីមនុស្សបង្ក ឡើង ។ ព្រៃអំបូរឈើផ្ទៃមានស្នាបពីរស្ងួត ជាទូទៅមានពន្លឺច្រើន ។ ព្រៃល្បោះដែលមិនទាន់មានការប៉ះពាល់ អាចមានកន្សោមស្លឹក ៤០% ។ ដី និង ស្មៅអាចមានឥទ្ធិពលខ្លាំងលើការឆ្លុះត្រឡប់ពណ៌ពីព្រៃទាំងនេះ ។ ដូច្នេះ គេលំបាកនិងបែងចែកព្រៃល្បោះដាច់ពីព្រៃគុម្ពោធក្នុងរដូវប្រាំង ។

ព្រៃប្រភេទផ្សេង១: ជាតំបន់ត្រូបដោយ ដំណុះឈើថ្មី ព្រៃក្រិន ព្រៃកោងកាង ព្រៃលិចទឹក និងចំការព្រៃដាំ ។ ដំណុះឈើព្រៃថ្មីធម្មតា គឺដុះក្រាសជាប់១ឆ្នា ជាស្រទាប់ដើមឈើតូច១ ។ ព្រៃក្រិនដុះលូតលាស់យឺតណាស់ ដោយសារតែមានលក្ខខណ្ឌមិនល្អ ដីជាទឹក និងសំបូរថ្ម ។ ព្រៃរងការបំផ្លាញខ្លាំង ដូចជាព្រៃដុះដោយដុំ១ ដំណុះព្រៃឡើងវិញ ដំណាំកសិកម្មពនេចរ ដែលមានភាគរយព្រៃច្រើនជាង៤០% និងតំបន់មានដំណុះព្រៃចាស់ និងព្រៃក្មេងជំនាន់ទី២ក្រោយពីការកាប់ឆ្លា ក៏ស្ថិតក្នុងប្រភេទព្រៃនេះដែរ ។

ព្រៃគុម្ពោធបៃតង: ជាព្រៃដែលមានស្មៅ និងដើមឈើតូច១ដុះលាយឡំគ្នា ។ តំរបម្ជប់មានតិចជាង២០% ។ ប្រភេទព្រៃនេះ គេឃើញមាននៅលើតំបន់ដែលមានស្រទាប់ដីរាក់១ លើកំពូលភ្នំក្រោមលក្ខខណ្ឌអាកាសធាតុផ្សេង១ ដែលមិនមានប្រើប្រាស់ដោយចិរភាព ។ តាមទ្រឹស្តី គឺមានឱកាស ក្លាយជាព្រៃម្ពងទៀត ។ អត្តសញ្ញាណនៃប្រភេទព្រៃនេះក្នុងរូបភាពគឺមានពណ៌ក្រហមត្រឿងពេញមួយឆ្នាំ ។ ដំណុះឈើថ្មី១ ក្រោយពីការធ្វើកសិកម្មពនេចរ ក៏ចាត់ទុកក្នុងប្រភេទព្រៃនេះដែរ ។ ជាធម្មតា គឺមានស្រទាប់ក្រាសមួយនៃគុម្ពឈើ និងវាលស្មៅដែលមានដើមឈើខ្លះ១ ។

ព្រៃគុម្ពោធស្ងួត: ជាប្រភេទព្រៃស្ងួតដែលឃើញមាននៅលើខ្ពង់រាប តែក៏មាននៅលើទីជ្រាលស្ងួតនិងត្រូវថ្ងៃដែរ ។ អត្តសញ្ញាណសំគាល់នៅលើរូបភាពផ្កាយរណបមានពណ៌ប្រផេះស្លេងនៅរដូវប្រាំង និងមានពណ៌ប្រផេះលាយត្នោតខ្ចីទៅពណ៌ស្វាយនៅរដូវវស្សា សាច់ពណ៌ពីល្មមទៅត្រើម ។

ព្រៃឫស្សី: តំបន់ចំទួលាយដែលមានព្រៃឫស្សីក្រាស់ ជាទូទៅ ក្នុងរូបភាពផ្កាយរណប គេសំគាល់ឃើញថា មានពណ៌ផ្កាឈូក និងពណ៌ទឹកក្រូច និងតាមសាច់ពណ៌របស់វា ។ ព្រៃឫស្សីស្លេង១ រ៉ុយ១ ឬតូច១ នឹងមិនអាចសំគាល់បានទេ ហើយអាចចាត់ទុកជាព្រៃប្រភេទផ្សេង១ ។

ដីមិនមែនព្រៃឈើ: ចំណាត់ថ្នាក់នេះ ជាតំបន់រួមញ្ចានៃ ដីកសិកម្ម ទីប្រជុំជន ផ្ទៃទឹក វាលស្មៅ និងដីវាលញ្ចានរុក្ខជាតិ ។